# សិលាចារឹកមកពីខេត្តប៉ៃលិន (K.1553)

សព្វថ្ងៃ សិលាចារឹកនេះកំពុងរក្សាទុកនៅឃ្លាំងសារមន្ទីរ នៃមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្តតាកែវ។ កាលដើមឡើយ លោក មីសែល ត្រាណេ បានចុះបញ្ជីសិលាចារឹកនេះលេខ Ka.36 តែក្រោយមកសាលាបារាំងចុងបូព៌ាប្រទេស ចុះលេខបញ្ជីថ្មី K.1553។ យោងតាមរបាយការណ៍របស់មន្ទីរ បានបញ្ជាក់ឱ្យដឹងថា សិលាចារឹកនេះរត់ពន្ធចេញមកពីខេត្តប៉ៃលិន។ ប៉ុន្តែ គេមិនបានបញ្ជាក់ច្បាស់លាស់អំពីទីតាំងដើមច្បាស់លាស់ណាមួយនៅក្នុងខេត្តប៉ៃលិនឡើយ។ ទោះបីជាយ៉ាងណា ផ្អែកទៅតាមខ្លឹមសាររបស់សិលាចារឹក ដែលរៀបរាប់អំពីដែនដីស្ថិតនៅក្រោមការគ្រប់គ្រងរបស់ព្រះបាទស្រីឦសានវម៌្ម (ទី១) សិលាចារឹកនេះប្រហែលអាចមានប្រភពដើមមកពីតំបន់ណាមួយនៃខេត្តតាកែវ។ កន្លងមក សិលាចារឹកនេះពុំធ្លាប់មានអ្នកស្រាវជ្រាវបានសិក្សា និងបកប្រែនៅឡើយទេ។ តើសិលាចារឹកនេះ មានខ្លឹមសារ និងអត្ថន័យយ៉ាងដូចម្ដេចខ្លះ?

អត្ថបទសិលាចារឹកនេះ សរសេរជាភាសាសំស្ក្រឹតមានចំនួន ១០ បន្ទាត់ ស្មើនឹង ១០ ស្លោក ដែលជាប្រភេទបង្គោលសីមាថ្មភក់ ចារឹកនៅសម័យមុនអង្គរ ពោល គឺមានបញ្ជាក់កាលបរិច្ឆេទជាក់លាក់នៅក្នុងមហាសករាជឆ្នាំ ៥៤៩ ត្រូវនឹងគ្រិស្តសករាជឆ្នាំ ៦២៧ (រជ្ជកាលព្រះបាទស្រីឦសានវម៌្មទី១ គ.ស.៦១៦ - ៦៣៧)។ គួរកត់សម្គាល់ជាពិសេស សិលាចារឹកនេះរៀបរាប់អំពីព្រះកិត្តិនាមដ៏ល្បីល្បាញក្នុងការដឹកនាំរដ្ឋរបស់ព្រះបាទស្រីឦសានវម៌្មទី១ និងរៀបរាប់អំពីរដ្ឋមន្ត្រីរបស់ព្រះអង្គម្នាក់ ដែលមាននាមថា "**វិទ្យាវិសេស**" ដែលទ្រង់បានតែងតាំងឱ្យកាន់មុខតំណែងជា "**ជិតសាស្ត្រ**" (តម្រាស្ដីអំពីជ័យជម្នះ) ហើយលោកគឺជាអភិបាលក្រុងតមន្ទបុរ។ រដ្ឋមន្ត្រី និងជាអភិបាលក្រុងតមន្ទបុរម្នាក់នេះ ធ្លាប់មានរៀបរាប់នៅក្នុងសិលាចារឹកមួយនៅក្រុមប្រាសាទយាយព័ន្ធ ចុះបញ្ជីលេខ K.604 ដែលកាលបរិច្ឆេទគឺដូចគ្នាតែម្ដង (ម.ស.ឆ្នាំ ៥៤៩) និងមានរៀបរាប់នៅក្នុងសិលាចារឹក K.9 ដែលរកឃើញនៅតំបន់សាដែក ខេត្តអានយ៉ាង (តំបន់ដីសណ្ដទន្លេមេគង្គភាគខាងត្បូងប្រទេសវៀតណាមបច្ចុប្បន្ន) ដែលលោក Dominic Goodall ធ្លាប់សិក្សានិងសន្និដ្ឋានថា ប្រហែលជាអតីតទីកដីទីក្រុងតមន្ទបុរ។

ចំពោះខ្លឹមសារជារួមនៃសិលាចារឹកនេះ រៀបរាប់អំពី៖

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់

- *ស្លោកទី១ ជាស្លោកនមស្ការគោរពវន្ទាដល់ព្រះភគវាន់សិវ ដែលព្រះកាយទ្រង់ទ្រទ្រង់ដោយធាតុទាំង៨ ឬហៅថា "**អស្តមូតិ៌**"។*
- *ស្លោកទី២ ពណ៌នាអំពីព្រះបាទគ្រីញ្ញ៉ុគានវម៌្មទី១។*
- *ស្លោកទី៣ ពណ៌នាអំពីព្រះកិត្តិគុណ។*
- *ស្លោកទី៤ ពណ៌នាអំពីដែនវិសាលភាពអំណាចរបស់ព្រះបាទគ្រីញ្ញ៉ុសានវម៌្មទី១។*
- *ស្លោកទី៥ និងទី៦ ពណ៌នាអំពីគុណសម្បត្តិយុធិសាស្រ្តសង្រ្គាម ចរិយាសម្បត្តិ សីលធម៌ និងរូបសម្បត្តិរបស់ព្រះបាទគ្រីញ្ញ៉ុគានវម៌្មទី១។*
- *ស្លោកទី៧ ពណ៌នាអំពីរដ្ឋមន្ត្រីដែលព្រះមហាក្សត្រត្រាស់បង្គាប់តែងតាំង។*
- *ស្លោកទី៨ ពណ៌នាអំពីរដ្ឋមន្ត្រីឈ្មោះ វិទ្យាវិសេស ដែលទទួលបានការតែងតាំងពីព្រះបាទគ្រីញ្ញ៉ុគានវម៌្មទី១។*
- *ស្លោកទី៩ ពណ៌នាអំពីកាលបរិច្ឆេទ មហាសករាជឆ្នាំ ៥៤៩។*
- *ស្លោកទី១០ ពណ៌នាអំពីរដ្ឋមន្ត្រី "វិទ្យាវិសេស" ទទួលបានតែងតាំងក្នុងមុខតំណែងជាអភិបាលទីក្រុងតមន្ទរបុរ។*

## អត្ថបទចារឹក និងសេចក្តីប្រែ

១. [សមស្តាស?]មតៃត្វយ៌្យ- ប្រធានប្រកុរីត្វរះ
ជាយ៌្យតេ ជគជម្ភាភិ- រគេម យស្យ មូត្តិ៌ភិះ។

***ប្រែថា៖*** *ព្រះប្រកុរីត្វរ (ពោលគឺព្រះសិវ) ទ្រង់ជាអ្នកប្រទាននូវឥស្សរភាព [ជាទេពមិនមានអ្វីទាំងឡាយណាអាចប្រៀបស្មើបាន] អ្វីគ្រប់យ៉ាងគ្មានសេសសល់ក្នុងលោក គឺត្រូវបានទ្រទ្រង់ដោយព្រះអស្តមូតិ៌របស់ទ្រង់។*

២. [សវ៌េឌេគេមុ?] ភ្វចាល- មស្តកាប្ឹ្បតគាសនះ

*អត្ថបទដោយ៖ កំ វណ្ណាព៉ា និងព្រះតេជគុណ អេង សុគង់*

រាជា ត្រិភានវម៌្មេតិ យតាមេកកាជនមិ។

***ប្រែថា៖*** *មានព្រះរាជាមួយអង្គ មានព្រះនាមថា ត្រីភៀគានវម៌(ទី១) ទ្រង់មានព្រះរាជសាសន៍ (គឺព្រះរាជបញ្ជា) ត្រូវបានលើកគោរពទូលលើត្បូងដោយពួកស្ដេចផែនដី [ក្នុងប្រទេសទាំងឡាយ] ទ្រង់ប្រៀបដូចជាភាជន៍មួយនៃយសានុភាពគ្រប់យ៉ាង។*

៣. ..........ភូមិភាត្យត៌្ម- មគោភតយគោជនះ
អន្វយេ យោ ជគន្ឡាបិ យកសាមវជីកុជាមិ។

***ប្រែថា៖*** *ព្រះអង្គ ដូច...........នឹងចំណង់ដ៏ក្រៃពេក ទ្រង់ជម្រះស្អាតដោយការប្រយុទ្ធនឹងភាពសៅហ្មង ទ្រង់ក៏បានយកព្រះទ័យទុកដាក់អំពីដែនដីរបស់ស្ដេចផែនដីដ៏មានយសានុភាពទាំងឡាយក្នុងសន្តតិវង្ស (របស់ព្រះអង្គកន្ទងមក) ។*

៤. ឧជជិត្រែយបយ៌្យន្ត- មេកាច្ឆត្រែវតំ សិតមិ
យស្យ ប្រែតបតស្សម្យ- កក្ខជវជិមណ្ឌលមិ។

***ប្រែថា៖*** *(ដូច្នេះហើយ) ព្រោះអំណាចដ៏ក្រៃលែងរបស់ព្រះអង្គ មណ្ឌលដែនដីក៏ត្រូវបានរួបរួមឱ្យស្ថិតក្រោម(ស្វេត)ឆត្រតែមួយរហូតដល់ត្រើយម្ខាងនៃសមុទ្រទាំង ៣។*

៥. អាក្សេត្តោ យេជ មហាតះ កាមុកស្យជគោវលមិ
ជិលីបស្យាបិរាជម៌ រសេមះប្រែជិគោរណះ។

***ប្រែថា៖*** *ព្រះអង្គមានភាពមហិមាណាស់ក្នុងសមរភូមិ មិនត្រឹមតែអាចប្រដូចទៅនឹងព្រះកាមទេពទេ សូម្បីស្ដេចទិលីបជាចម្បងលើស្ដេចទាំងឡាយ ដែលល្បីល្បាញលើយុទ្ធភូមិក៏ទ្រង់ស្មើដូច។*

៦. [ប្រែ]ម្យេវរូបសំបត្តិ- វិតិរូហាមហត្ថិតីមិ

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

អត្យជន្ទនជោមជ្យេ វបុម្ម្នន្តមវេក្ស្យយមិ។

***ប្រែថា៖*** *ព្រះអង្គមានព្រះរូបសម្បត្តិគួរជាទីប្រិមប្រិយណាស់ ទ្រង់មិនប្រកាន់មាំព្រោះកំហឹង ទូលព្រះបង្គំជាខ្ញុំមានសេចក្តីគោរពស្រលាញ់ដ៏ស្មោះស្ម័គ្រ បានគិតនិងជាអ្នកបានឃើញជាក់ស្តែងនូវអវយវៈព្រះវរកាយនេះ (របស់ព្រះអង្គ) ។*

៧. [តេ]ឝរាជាធិរាជេឝ ប្រេជ[មក]វេធិនាមិ
សភ៌ាក្ស្វធិក្ស្វតោភ្វត្យ ឥតិកាត៌្យ្យតាសុយ។

***ប្រែថា៖ ព្រះរាជាធិរាជអង្គនេះ*** *បណ្តាពួកមន្ត្រីជួរមុខទាំងឡាយ គឺមានមន្ត្រីម្នាក់ ទ្រង់បានតែងតាំងជាមន្ត្រីផ្នែកសព្វាធិការកិច្ច លើកាតព្វកិច្ចទាំងឡាយ។*

៨. [លិ]ខិតេធិតតា ស្ត្រាណាំ ធុរិយះ កាមិរាធិនាមិ
វិទ្យាវិសេឞ ជាមាភូ ជាចាយ៌្យគុរុវត្សលមិ។

***ប្រែថា៖*** *មុខតំណែងទាំងឡាយ មានជាអាទិ៍ជាប្រធានក្នុងការកត់ត្រានៃ**ជិតសាស្ត្រ** (គឺតម្រាស្តីអំពីជ័យជម្នះ)ទាំងឡាយ។ មន្ត្រីរូបនោះមាននាមថា **វិទ្យាវិសេស** ជាព្រះអាចារ្យដែលជាទីគោរពស្រឡាញ់ពីសំណាក់គ្រូៗទាំងឡាយផង។*

៩. ពណិតេព្វេទកោឆ្ទ្រូស្យ ទ្វារម្ភោជនិធិសាយកៃះ
តេឆសេតុរយំ វទ្ធ ស្បួសង្គ្រាមទ្វយកុណ្ឌា[ណ្ឌា]លមិ។

***ប្រែថា៖*** *កាលបើគិតគណនាតាមឆ្នាំនៃស្តេចសក គឺក្នុងឆ្នាំ៥៤៩ មានស្ពានមួយត្រូវបានចងព័ទ្ធសង្កាត់ដោយប្រវាក់ពីរសងខាងតាមច្រកចេញចូលដោយរូបគាត់។*

*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*

១០. [ស្វ]កាបុណ្យោព្វជិតា[ព្រណា]    ឆ្ស្យឃ្វាតេនក្វកុដាំ
តមន្ទរបុរស្វាមិ-    ភោជកាត្វេនិយោជិតះ។

*ប្រែថា៖ ព្រោះអំណាចនៃគុណបុណ្យទាំងឡាយ [របស់ខ្លួន] ដែលលោកបានគោរពបូជាកន្ទងមកចំពោះស្តេចផែនដីទាំងឡាយ តាមរយៈព្រះរាជាអង្គនេះលោកត្រូវបានតែងតាំងក្នុងមុខតំណែងជាមេតំបន់ដែលជាម្ចាស់ស្ថិតឰដ៏ទីក្រុងតមន្ទរបុរ។*

*សរុបជារួមមក សិលាចារឹកដែលកំពុងរក្សាទុកនៅសារមន្ទីរខេត្តតាកែវ* (K.1553) *បានផ្តល់ព័ត៌មានមួយចំនួន ពាក់ព័ន្ធទៅនឹងដែនវិសាលភាពអំណាចរបស់ព្រះបាទស្រីឦសានវម៌្មទី១ នៅក្នុងមហាសករាជឆ្នាំ ៥៤៩ ត្រូវនឹងគ្រិស្តសករាជឆ្នាំ៦២៧ ដែលគ្រប់គ្រងរហូតដល់ត្រើយម្ខាងនៃសមុទ្រទាំងបី។ ព្រមទាំងបានបង្ហាញអំពីរដ្ឋមន្ត្រីឈ្មោះ វិទ្យាវិសេស ដែលព្រះមហាក្សត្របានតែងតាំងជាអភិបាលក្រុងតមន្ទបុរ។*

*ឯកសារពិគ្រោះ*


**Dominic Goodall**,

‘Noble, Bureaucrats or Strongmen? On the “VASSAL KING” or “Hereditary governors” of Pre-Angkoian City-Sates: Two Sanskrit Inscriptions of Vidyāvisesa, Seventh-Century Governor of Tamandrarapura (K.1235 and K.604), and An Inscription of Śivadatta (K. 1150), Previously Considered a Son of Isahnavarman I, in *UDAYA*, Volume 14. 2019.


*អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់*



រូបលេខ១៖ សិលាចារឹកមកពីខេត្តប៉ៃលិន (K.1553)

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់



រូបលេខ២២៖ សំណៅផ្តិតសិលាចារឹកមកពីខេត្តប៉ៃលិន (K.1553)

(ផ្តិតដោយ៖ កំ វណ្ណារ៉ា)

អរិយធម៌ខ្មែរ
KHMER CIVILIZATION

អត្ថបទដោយ៖ កំ វណ្ណារ៉ា និងព្រះតេជគុណ អេង សុគង់